**នរោត្តម  សីហនុ**
**នៃកម្ពុជា**

ជូន ឯកឧត្តម គាត ឈន់
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ឯកឧត្តមជាទីរាប់អានដ៏ខ្ពង់ខ្ពស់ និងស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត

ខ្ញុំបានទទួលហើយលិខិតថ្វាយពរដ៏ល្អប្រពៃរបស់ឯកឧត្តម នៅក្នុងឱកាសពិធីបុណ្យចំរើនជន្មាយុខ្ញុំ។

ខ្ញុំសូមសំដែងនូវអំណរគុណដ៏ជ្រាលជ្រៅ ចំពោះយុត្តិធម៌ដែលឯកឧត្តមផ្តល់ជូនសង្គមរាស្ត្រនិយម និងដល់ខ្ញុំ ក្នុងការបំរើប្រជាជាតិ មាតុភូមិ និងប្រជារាស្ត្រកម្ពុជា។

នៅក្នុងឱកាសដ៏ល្អប្រពៃនេះ ខ្ញុំសូមសរសើរដ៏កក់ក្តៅជាទីបំផុតឯកឧត្តមដែលស្នេហាជាតិជាដរាប និងបំពេញភារកិច្ច ទទួលបានជោគជ័យ ដើម្បីជាឧត្តមប្រយោជន៍ប្រជាជាតិ និងប្រជារាស្ត្រកម្ពុជា។

ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានប្រកបតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមឯកឧត្តម និងលោកជំទាវ ទទួលនូវសេចក្តីរាប់អានដ៏ខ្ពង់ខ្ពស់ និងស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត អំពីខ្ញុំ និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ។

**នរោត្តម  សីហនុ**

ប៉េកាំង ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១០